ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
"រ.ទ.ស.ភ"

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាភិបាលវិសាមញ្ញ លើកទី១ ឆ្នាំ២០១៧ របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
## ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ(រ.ទ.ស.ភ) សូមជម្រាបជូនវិនិយោគិន និងសាធារណជនមេត្តាជ្រាបថា នៅរសៀល ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧ វេលាម៉ោង ១៤:០០នាទី **ឯកឧត្តម សឹម ណារ៉ា** ជាប្រធានក្រុមប្រឹក្សាភិបាល រ.ទ.ស.ភ បានអញ្ជើញចូលរួមជាអធិបតី ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលវិសាមញ្ញ លើកទី១ ឆ្នាំ២០១៧ របស់ រ.ទ.ស.ភ នៅទីចាត់ការប្រតិបត្តិនៃ រ.ទ.ស.ភ ។

នៅក្នុងកិច្ចប្រជុំនេះ ក្រុមប្រឹក្សាភិបាលបានពិនិត្យ និងពិភាក្សាផ្លាស់ប្តូរយោបល់លើខ្លឹមសារលម្អិតនៃរបាយការណ៍ ដែលបង្ហាញដោយមន្ត្រីជំនាញ រ.ទ.ស.ភ តាមរបៀបវារៈដែលបានកំណត់ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

១. រ.ទ.ស.ភ ត្រូវរៀបចំគណៈកម្មការ ដើម្បីដោះស្រាយការងារផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋរស់នៅក្នុងសង្កាត់ក្បាលកោះ ព្រែកឯង ព្រែកថ្មី និងវាលស្បូវ ក្នុងខណ្ឌច្បារអំពៅ ដោយអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

២. អនុវត្តតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា រ.ទ.ស.ភ ត្រូវរៀបចំសំណើសុំទៅក្រសួងអាណាព្យាបាល លើករណីកែប្រែតម្លៃលក់ទឹកស្អាតរបស់ រ.ទ.ស.ភ ។

នៅក្នុងរបៀបវារៈផ្សេងៗ ក្រុមប្រឹក្សាភិបាលបានអនុម័តឱ្យ រ.ទ.ស.ភ ទូទាត់ជូនក្រុមហ៊ុន VINCI Construction Grands Projets នូវអាករលើតម្លៃបន្ថែម (VAT) ក្នុងគម្រោងសាងសង់រោងចក្រនិរោធ ជំហាន២។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង ១៦:៣០នាទី នាថ្ងៃ ខែ និងឆ្នាំដដែល ស្ថិតក្រោមបរិយាកាសទទួលខុសត្រូវខ្ពស់ និងឯកភាពគ្នា។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមវិនិយោគិន និងសាធារណជនទទួលជ្រាបជាព័ត៌មាន។

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៧
**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

អាសយដ្ឋានៈ លេខ៤៥ ផ្លូវ ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ទូរស័ព្ទៈ ៨៥៥ (២៣) ៧២៤ ០៤៦ Email: admin@ppwsa.com.kh